01363641

លេខ៖ ៩៣៦/I

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 12 / 2016
ម៉ោង (Time/Heure) : 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក -ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦**

ភាសា ៖ **អង់គ្លេស & ខ្មែរ**

ចំណាត់ថ្នាក់ឯកសារ ៖ **សាធារណៈ**

---

## ដីកាសម្រេចបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤

---

**ផ្ញើជូន៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES NZEPA
Herve DIAKIESE
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") បានជូនដំណឹងជាសាធារណៈទៅភាគីទាំងអស់ និងមេធាវីរបស់ភាគីទាំងអស់អំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន[1]។

## II. ពិភាក្សា

២. មាត្រា ១៤ (៣)(គ) នៃ*កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឆ្នាំ* ១៩៦៦ ចែងថា ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះដោយឥតពន្យារពេលយូរហួស។ វិធានផ្ទៃក្នុង ២១ (៤) តម្រូវថា ការសម្រេចសេចក្តីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប។ ដោយយល់ឃើញថា កិច្ចស៊ើបសួរលើការចោទប្រកាន់ប្រឆាំង អោ អាន បានបញ្ចប់ហើយខណៈដែលកិច្ចស៊ើបសួរប្រឆាំង យឹម ទិត្យ នៅក្នុងសំណុំរឿង ០០៤ នៅបន្តដំណើរការនោះ ទើប យើងយល់ឃើញថា ជាការត្រឹមត្រូវ និងដើម្បីជាប្រយោជន៍ភាគីទាំងអស់ គឺត្រូវបំបែកសំណុំរឿង អោ អាន ចេញពីសំណុំរឿង ០០៤។

៣. វិធាន ៦៧ នៃវិធានផ្ទៃក្នុង តម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ចេញនូវដីកាដំណោះស្រាយ ដែលអាចជាការលើកលែងការចោទប្រកាន់ ឬ បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ទោះបីជាវិធាននេះ មិនមានកំណត់ពេលវេលាជាក់លាក់ ក៏ប៉ុន្តែ អនុលោមតាមវិធាន ២១(៤) សហចៅក្រមស៊ើបអង្កេត មានកាតព្វកិច្ចក្នុងការចេញដីកាដំណោះស្រាយក្នុងពេលវេលាសមស្រប។

៤. យើងជឿជាក់ថា ការបំបែកសំណុំរឿងនេះនឹងចៀសវាងមិនឱ្យមានការពន្យារពេលសំណុំរឿង អោ អាន ឱ្យយូរហួសឡើយ ហើយក៏មិនប៉ះពាល់ដល់សិទ្ធិរបស់ភាគីណាមួយឡើយខណៈដែលអង្គហេតុដែលសេសសល់ទាំងអស់នៅក្នុងសំណុំរឿង ០០៤ នៅបន្តស៊ើបសួរ។

---

[1] សំណុំរឿង ០០៤ ឯកសារ D334 *សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង អោ អាន* ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។

01363643



**តាមសំអាងហេតុខាងលើ យើង[2]៖**

៥. **បង្គាប់ឲ្យ** បំបែកនីតិវិធីពាក់ព័ន្ធនឹង អោ អាន ចេញពីសំណុំរឿង ០០៤។

៦. **បង្គាប់** ក្រឡាបញ្ជី ត្រូវធ្វើការចាត់ចែងដែលចាំបាច់ដើម្បីបង្កើតសំណុំរឿងថ្មី ដាក់លេខ ០០៤/២ ដែលអាចចូលពិនិត្យមើលបានពីសំណាក់ភាគីទាំងអស់ ដែលបច្ចុប្បន្ននេះមានសិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤។

៧. **ជូនដំណឹង** មេធាវីការពារក្តី យឹម ទិត្យ និងមេធាវីការពារក្តី អ៊ឹម ចែម ថា ពួកគាត់នឹងទទួលបានសិទ្ធិចូលពិនិត្យមើលសំណុំរឿង០០៤/២ ពីព្រោះថា ការដាក់ឯកសារ និងសេចក្តីសម្រេចនានាដែលបានចេញនៅក្នុងសំណុំរឿងនេះនាពេលអនាគតអាចពាក់ព័ន្ធនឹងការតំណាងឲ្យកូនក្តីរបស់ខ្លួននៅក្នុងសំណុំរឿង ០០៤ និង០០៤/១។ ប៉ុន្តែ សិទ្ធិចូលពិនិត្យមើលសំណុំរឿង ០០៤/២ មិនមែនមានន័យជាស្វ័យប្រវត្តិថាមានសិទ្ធិដាក់ញត្តិ ឬសំណើនៅក្នុងសំណុំរឿងនេះទេ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦

**សហចៅក្រមស៊ើបអង្កេត**

Co-Investigating Judges

Co-juges d'instruction

**ចៅក្រម យូ ប៊ុនឡេង ចៅក្រម Michael BOHLANDER**

[2]ស.ច.ស ចេញសេចក្តីជូនដំណឹងនេះរួមគ្នា ប៉ុន្តែ ដើម្បីជាកំណត់ហេតុ ស.ច.ស ជាតិ សូមកត់សម្គាល់ថា ឯកសារដែលបានដាក់ចូលក្នុងសំណុំរឿង ០០៤ គួរដាក់លេខបន្តពីឯកសារចុងក្រោយដែលបានដាក់មុនពេលចៅក្រម Siegfried Blunk បានលាលែងតំណែង ដោយមិនរាប់បញ្ចូលដីកា និងដីកាសម្រេចនានាដែលចេញដោយ ស.ច.ស បម្រុង Kasper-Ansermet ឡើយ។